# ការគ្រប់គ្រងដោយឈឺឆ្អាល

SUN Leangheng

# មាតិកា


១. គោលគំនិត

២. សញ្ញាណគតិយុត្ត

២.១. អត្ថន័យ

២.២. លក្ខខណ្ឌ

៣. សិទ្ធិ និង ករណីយកិច្ច

៣.១. សិទ្ធិ

៣.២. ករណីយកិច្ច

# គោលគំនិត

- លើកទឹកចិត្តឱ្យចេះជួយគ្នាក្នុងសង្គម
- ការពារដល់អ្នកដែលមានសណ្ដានចិត្តចេះជួយគ្នា
- បង្ការកុំឱ្យយកការគ្រប់គ្រងដោយឈើឆ្កាលដើម្បីកេងយកប្រយោជន៍
- ការទទួលបាននូវការតបស្នងសមរម្យ

# អត្ថន័យនៃការគ្រប់គ្រងដោយឈើឆ្កាល

- អត្ថន័យតាមពាក្យពេចន៍
- អត្ថន័យតាមក្រមរដ្ឋប្បវេណីសង្គមចាស់
- អត្ថន័យតាមក្រមរដ្ឋប្បវេណីបច្ចុប្បន្ន

# អត្ថន័យតាមពាក្យពេចន៍

ការគ្រប់គ្រងដោយឈឺឆ្អាល

= ការគ្រប់គ្រង + ការឈឺឆ្អាល

# អត្ថន័យនៃការគ្រប់គ្រង

- ការគ្រប់គ្រង អាចជាការគ្រប់គ្រងលើមនុស្ស និង ការគ្រប់គ្រងលើវត្ថុ។
- ការគ្រប់គ្រងលើមនុស្ស អាចជាការគ្រប់គ្រងលើបុគ្គលដែលស្ថិតក្នុងបន្ទុកគ្រួសារ និង ការគ្រប់គ្រងបុគ្គលិក/មន្ត្រីក្រោមឱវាទ ។
- ការគ្រប់គ្រងលើវត្ថុ អាចជាការគ្រប់គ្រងវត្ថុជាកម្មសិទ្ធិផ្ទាល់ខ្លួន និង ការគ្រប់គ្រងវត្ថុជាកម្មសិទ្ធិអ្នកដទៃ។
- ការគ្រប់គ្រងវត្ថុដែលជាកម្មសិទ្ធិអ្នកដទៃ អាចជាការគ្រប់គ្រងតាមរយៈកិច្ចសន្យា និង ដោយគ្មានកិច្ចសន្យា។

# អត្ថន័យនៃការគ្រប់គ្រង (ត)

- ការគ្រប់គ្រង អាចជាការគ្រប់គ្រងដោយផ្ទាល់ និង ការគ្រប់គ្រងដោយប្រយោល។
- ការគ្រប់គ្រង នាំឱ្យមានការពិចារណា ទៅលើរបៀបនៃការគ្រប់គ្រង។ ដែលជាគោលការណ៍ ការគ្រប់គ្រង ត្រូវចាំបាច់នាំឱ្យមានលក្ខណៈល្អប្រសើរ ត្រឹមត្រូវ និង ជាទុកចិត្តបាន។
- ការគ្រប់គ្រង បានបង្កប់នូវការទទួលបាននូវតម្លៃតបស្នង ឬ ផលកម្រៃដែលបានមកពីការគ្រប់គ្រង។

# អត្ថន័យនៃការគ្រប់គ្រង (ត)

- ការគ្រប់គ្រង នាំឱ្យមានការចំណាយលើការគ្រប់គ្រង ដែលគួរពិចារណាលើបន្ទុកក្នុងការចំណាយ។
- ការគ្រប់គ្រង នាំឱ្យមានការទទួលខុសត្រូវលើការគ្រប់គ្រង ករណីមានព្យសនកម្មកើតឡើងដោយសារការគ្រប់គ្រងរបស់អ្នកគ្រប់គ្រង។

# អត្ថន័យនៃការឈឺឆ្អាល

- ការឈឺឆ្អាល គឺជាការយកអាសា ជួយធ្វើការជួយដោះទុក្ខធុរៈគេផ្សេងៗ។
- ការឈឺឆ្អាល នាំឱ្យមានការគិតដល់ថា មានកិច្ចការដែលត្រូវបំពេញ ឬ បញ្ហាបានកើតឡើង ដែលមិនមែនជាបញ្ហារបស់ខ្លួន។
- ការឈឺឆ្អាល សំដៅលើបុគ្គលដែលឈឺឆ្អាល មិនមានការទទួលបានសិទ្ធិអំណាចក្នុងការដោះស្រាយពីដំបូង ឬ គ្មានការយល់ព្រមឱ្យដោះស្រាយបញ្ហាជាមុនឡើយ។
- ការឈឺឆ្អាល ឱ្យមានការពិចារណាដល់ថា ការបំពេញកិច្ចទាំងឡាយ គឺដើម្បីផលប្រយោជន៍អ្នកដទៃ ដែលមិនមែនជាប្រយោជន៍របស់អ្នកឈឺឆ្អាលនោះទេ។

# អត្ថន័យនៃការឈឺឆ្អាល (ត)

- ការឈឺឆ្អាល នាំឱ្យមានការដឹងគុណពីអ្នកមានបញ្ហា ឬ ការមិនសប្បាយចិត្តពីអ្នកមានបញ្ហា ។
- ការឈឺឆ្អាល នាំឱ្យមានការបំពេញកិច្ចការណាមួយ ឬ ច្រើន។

# ការគ្រប់គ្រងដោយឈឺឆ្អាល

- ការគ្រប់គ្រងដោយឈឺឆ្អាល គឺជាការគ្រប់គ្រងលើមនុស្ស ឬ វត្ថុ ដែលស្ថិតនៅក្នុងបន្ទុក ឬជាកម្មសិទ្ធិរបស់អ្នកដទៃ។
- ការគ្រប់គ្រងដោយឈឺឆ្អាល គឺជាការគ្រប់គ្រងដោយអ្នកគ្រប់គ្រងដោយឈឺឆ្អាល គ្មានសិទ្ធិអំណាចក្នុងការគ្រប់គ្រង។
- ការគ្រប់គ្រងដោយឈឺឆ្អាល នាំឱ្យអ្នកគ្រប់គ្រងដោយឈឺឆ្អាល អាចមានការចំណាយលើការគ្រប់គ្រង ដែលអ្នកគ្រប់គ្រង អាចនឹងត្រូវទទួលបានត្រលប់មកវិញ។

# ការគ្រប់គ្រងដោយឈឺឆ្អាល (ត)

- អ្នកគ្រប់គ្រងដោយឈឺឆ្អាល អាចត្រូវទទួលបានកម្រៃដែលបណ្ដាលមកពីការគ្រប់គ្រងរបស់ខ្លួន។
- ការគ្រប់គ្រងដោយឈឺឆ្អាល អាចនាំឱ្យអ្នកគ្រប់គ្រងទទួលខុសត្រូវនូវកំហុសរបស់ខ្លួន។

# អត្ថន័យតាមក្រមរដ្ឋប្បវេណីសង្គមចាស់

- មាត្រា ៨២៥ ចែងថា៖ “ជនណាឥតគេពឹងរក ហើយ ទទួលគ្រប់គ្រងនូវទ្រព្យសម្បត្តិនៃជនដទៃ ដោយឈឺឆ្អាលពីចិត្តឯង ជននោះត្រូវទទួលការគ្រប់គ្រង ត្រាតែម្ចាស់គេ មកគ្រប់គ្រងវិញខ្លួនឯងវិញ។
- ជននោះត្រូវយកចិត្តទុកដាក់ ចាត់ចែងការបីដូចជាឪពុក ដ៏ប្រពៃនៃត្រកូល គឺថាទុកខ្លួនឯងដូចម្ចាស់របស់ពិតៗ និងយកចិត្តទុកដាក់ នឹងផលប្រយោជន៍ទ្រព្យនោះផង។”

# អត្ថន័យតាមក្រមរដ្ឋប្បវេណីបច្ចុប្បន្ន

- មាត្រា ៧២៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី បានឱ្យនិយមន័យថា "ការគ្រប់គ្រងដោយឈឺឆ្អាល" សំដៅលើ ការចាប់ផ្ដើមគ្រប់គ្រងកិច្ចការដើម្បីបុគ្គលដទៃ ទោះបីជាគ្មានសិទ្ធិអំណាចក៏ដោយ។
- តាមអត្ថន័យនេះ ការគ្រប់គ្រងដោយឈឺឆ្អាល មិនបានកំណត់ឱ្យច្បាស់លាស់លើអំពី ការគ្រប់គ្រងលើ វត្ថុ ឬ មនុស្ស ដូចនៅក្នុងក្រមរដ្ឋប្បវេណីខ្មែរសង្គមចាស់នោះទេ ពោលគឺគ្រាន់តែបញ្ញត្តិពីការចាប់ផ្ដើមគ្រប់គ្រងកិច្ចការដើម្បីបុគ្គលដទៃ

# អត្ថន័យតាមក្រមរដ្ឋប្បវេណីបច្ចុប្បន្ន

<u>ឧទាហរណ៍</u>៖ លោក A បានចេញទៅលេងសៀមរាបចំនួន ០៣ ថ្ងៃ ដោយគ្មានអ្នកណានៅចាំផ្ទះទេ។ ខណៈនោះក៏មានភ្លៀង និងខ្យល់ខ្លាំងបានធ្វើឱ្យដំបូលផ្ទះរបស់លោក A បើងនិងធ្លុះធ្លាយដែលបណ្ដាលឱ្យមានភ្លៀងស្រក់លិចចូលក្នុងផ្ទះ។ លោក B ដែលជាអ្នកជិតខាងនិងលោក A បានឃើញដូចនោះ ក៏បានជួលឱ្យជាងទិញស័ង្កសីដើម្បីជួសជុលផ្ទះឱ្យលោក A។

# លក្ខណៈនៃការគ្រប់គ្រងដោយឈឺឆ្អាល

១. គ្មានសិទ្ធិអំណាចក្នុងការគ្រប់គ្រង

២. ដើម្បីបុគ្គលដទៃ

៣. ចាប់ផ្តើមគ្រប់គ្រងកិច្ចការ

៤. គ្រប់គ្រងតាមឆន្ទៈសាមីខ្លួន ឬ តាមសុចរិត

# គ្មានសិទ្ធិអំណាចគ្រប់គ្រង

- **គ្មានសិទ្ធិអំណាចតាមច្បាប់ និង កិច្ចសន្យា**
- **គ្មានសិទ្ធិអំណាចតាមច្បាប់**
  - បើជាការគ្រប់គ្រងលើបុគ្គល៖ អ្នកគ្រប់គ្រង មិនមែនជាអ្នកមានសិទ្ធិលើអ្នកដែលត្រូវគ្រប់គ្រង ដូចជា៖ មិនមែនជាអ្នកមានអំណាចមេបា អ្នកអាណាព្យាបាលទូទៅ ។ល។
  - បើជាការគ្រប់គ្រងលើវត្ថុ៖ អ្នកគ្រប់គ្រងមិនមែនជាអ្នកមានសិទ្ធិប្រត្យក្សលើវត្ថុ ។

# គ្មានសិទ្ធិអំណាចគ្រប់គ្រង (ត)

- **គ្មានសិទ្ធិអំណាចតាមច្បាប់**
  - ឧទាហរណ៍៖ ដូចជាប្រសិនបើថាំទន្លេជាត្រូវបាក់ដោយសារការកើនឡើងនៃទឹកទន្លេ ហើយមានអ្នករស់នៅក្បែរដងទន្លេណាម្នាក់ ចាត់វិធានការជាបន្ទាន់ដើម្បីទប់ច្រាំងបាក់ ដើម្បីការពារមិនមែនតែផ្ទះខ្លួនឯងប៉ុណ្ណោះទេ គឺដើម្បីការពារផ្ទះអ្នកជិតខាងដែរ សកម្មភាពបែបនេះនឹងត្រូវចាត់ទុកជាការគ្រប់គ្រងដោយឈឺឆ្អាល (សេក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគី ៣ គន្ថីទី ៥ ត្រង់មាត្រា ៧២៩)។ *តើជាការគ្រប់គ្រងដោយឈឺឆ្អាលឬទេ?*

# គ្មានសិទ្ធិអំណាចគ្រប់គ្រង (ត)

- **គ្មានសិទ្ធិអំណាចតាមកិច្ចសន្យា**
  - សាមីខ្លួនមិនបានប្រគល់សិទ្ធិឱ្យអ្នកគ្រប់គ្រង នៅមុនពេលការគ្រប់គ្រងចាប់ផ្ដើមឡើងឡើយ។
  - **ឧទាហរណ៍៖** លោក A បានឃើញផ្ទះលោក B ខូចបង្អួច ពេលនោះលោក A បានទូរស័ព្ទទៅលោក B ដើម្បីប្រាប់អំពីការណ៍នេះ លោក B ក៏បានស្នើសុំឱ្យលោក B ជួយជួសជុលឱ្យផង។ ករណីនេះ មិនស្ថិតក្នុងការគ្រប់គ្រងដោយឈឺឆ្អាលនោះទេ។

# ដើម្បីបុគ្គលដទៃ

- *តើបុគ្គលដទៃមានន័យដូចម្តេច?*
- **<u>ន័យទី១៖</u>** ***បុគ្គលដទៃ*** សំដៅលើ បុគ្គលទាំងឡាយណាដែលមិនមែនជាញាតិរបស់ខ្លួនឯង។
- **<u>ន័យទី២៖</u>** ***បុគ្គលដទៃ*** សំដៅលើបុគ្គលទាំងឡាយណាដែលក្រៅពីខ្លួនឯង។
- *តើន័យទី១ ឬ ន័យទី២ ដែលគួរប្រើក្នុងបរិបទនេះ?*

# ចាប់ផ្តើមគ្រប់គ្រងកិច្ចការ

- ការចាប់ផ្តើមបំពេញកិច្ចការ សំដៅ ការចាប់ផ្តើមបំពេញកិច្ចការគតិយុត្ត ដែលអាចជាបង្កើតកិច្ចសន្យាជាមួយ និង តតិយជន ឬ ធ្វើសកម្មភាពឯកតោភាគី ជាដើម ។ល។
- ឧទាហរណ៍៖ អ្នកជិតខាងរបស់លោក ក បានទៅទិញសង្កសី យកមកប្រក់ផ្ទះជូនលោក ក ដោយសារស័ង្កសីប៉ើងបណ្តាលមកពីភ្លៀងធំមួយមេ។
  - ទិញស័ង្កសី៖ ជាចុះកិច្ចសន្យាជាមួយនឹងអ្នកលក់
  - ប្រក់ដំបូល៖ ជាសកម្មភាពឯកតោភាគី

# តាមឆន្ទៈរបស់សាមីខ្លួន ឬ វិធីសមរម្យ

- ករណីបានដឹង ឬ អាចដឹងអំពីឆន្ទៈ៖ អ្នកគ្រប់គ្រង ត្រូវធ្វើការគ្រប់គ្រង ដោយផ្អែកតាមឆន្ទៈរបស់សាមីខ្លួននោះ។
- ករណីដែលមិនបានដឹង៖ អ្នកគ្រប់គ្រង ត្រូវធ្វើការគ្រប់គ្រងដោយព្យាយាមដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត តាមវិធីដែលសមរម្យជាគេ ដើម្បីប្រយោជន៍របស់សាមីខ្លួន ផ្អែកតាមលក្ខណៈនៃកិច្ចការ។

# សិទ្ធិរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

## ក. សិទ្ធិទាមទារសងសោហ៊ុយ

- សោហ៊ុយចំណាយនោះជាការចាំបាច់
- លើគ្រប់គ្រង និងថែរក្សាវត្ថុ ឬ ចំណាយបង្កើនតម្លៃ
- ការចំណាយដើម្បីសាមីខ្លួន

ប្រសិនបើការចំណាយនោះ ផ្ទុយពីឆន្ទៈរបស់សាមីខ្លួនវិញ អ្នកគ្រប់គ្រង អាចទាមទារឱ្យសាមីខ្លួន សងត្រឹមតែជាផលប្រយោជន៍ដែលសាមីខ្លួនបានទទួលជាក់ស្តែង

# សិទ្ធិរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

## ២. សិទ្ធិទាមទារកម្រៃ (មាត្រា ៧៣៥)

ក្នុងករណីដែលការគ្រប់គ្រងដោយឈឺឆ្អាលនោះ រួមបញ្ចូលនៅក្នុងវិជ្ជាជីវៈ ឬ អាជីវកម្មរបស់អ្នកគ្រប់គ្រងចំពោះកិច្ចការដែលនៅតែធ្វើបន្ត ក្រោយពេលដែលសាមីខ្លួន បានដឹងអំពីការគ្រប់គ្រងដោយឈឺឆ្អាលនោះរួចហើយ អ្នកគ្រប់គ្រងដោយឈឺឆ្អាល អាចទាមទារកម្រៃដែលត្រូវបង់ជាទូទៅ ចំពោះការគ្រប់គ្រងដោយឈឺ ឆ្អាលនោះបាន។

# ករណីយកិច្ចរបស់អ្នកគ្រប់គ្រង

ក. ករណីយកិច្ចជូនដំណឹង (មាត្រា ៧៣១)

ខ. ករណីយកិច្ចបន្តការគ្រប់គ្រង  (ម. ៧៣២)

គ. ករណីយកិច្ចរាយការណ៍ (ម. ៧៣៣ & ម. ៦៤១)

ឃ. ករណីយកិច្ចប្រគល់ (ម.៧៣៣ & ម. ៦៤២)

ង. ករណីយកិច្ចសងសំណងនៃការខូចខាត (ម. ៧៣៣ & ម. ៧៤៣)

ច.  ករណីយកិច្ចបំពេញកិច្ចដោយសុចរិត និង តាមឆន្ទៈរបស់សាម៉ីខ្លួន (ម. ៧២៩)

# ករណីយកិច្ចជូនដំណឹង

- តើអ្នកគ្រប់គ្រងដោយឈ្មួញធ្លាលត្រូវជូនដំណឹងនៅពេលណា?
- តើអ្នកគ្រប់គ្រងដោយឈ្មួញធ្លាលត្រូវជូនដំណឹងអំពីអ្វី?
- តើត្រូវជូនដំណឹងដល់អ្នកណា?
- តើការជូនដំណឹងនេះ ជាលក្ខខណ្ឌចាំបាច់ត្រូវតែធ្វើឬយ៉ាង?
- តើបុគ្គលក្រៅពីអ្នកគ្រប់គ្រងដោយឈ្មួញធ្លាលអាចធ្វើការជូនដំណឹង អាចចាត់ទុកជាការជូនដំណឹងដែរឬទេ?
- តើត្រូវជូនដំណឹងដោយរបៀបណា?

# ករណីយកិច្ចជូនដំណឹង (ត)

- *តើអ្នកគ្រប់គ្រងដោយឈីផ្លាលត្រូវជូនដំណឹងនៅពេលណា?*
  - <u>ត្រូវជូនដំណឹងនៅក្រោយ</u> ពេលការគ្រប់គ្រងដោយឈីផ្អាលបានចាប់ផ្តើម
- *តើអ្នកគ្រប់គ្រងដោយឈីផ្លាលត្រូវជូនដំណឹងអំពីអ្វី?*
  - ត្រូវជូនដំណឹងអំពីការបានចាប់ផ្តើមគ្រប់គ្រងដោយឈីផ្អាល
- *តើត្រូវជូនដំណឹងដល់អ្នកណា?*
  - ត្រូវជូនដំណឹងដល់សាមីខ្លួន

# ករណីយកិច្ចជូនដំណឹង (ត)

- *តើការជូនដំណឹងនេះ ជាលក្ខខណ្ឌចាំបាច់ត្រូវតែធ្វើឬយ៉ាង?*
  - ជាគោលការណ៍ អ្នកគ្រប់គ្រងដោយឈឺផ្ទាល ត្រូវជូនដំណឹងអំពីការបានចាប់ផ្ដើមការគ្រប់គ្រងដោយឈឺផ្ទាលទៅឱ្យសាមីខ្លួន ដោយគ្មានការយឺតយ៉ាវ។
  - លើកលែងតែ សាមីខ្លួនបានដឹងអំពីការគ្រប់គ្រងនោះហើយ ការជូនដំណឹងនេះមិនចាំបាច់ឡើយ (ម.៧៣១ វ.ទី២ នៃក្រមរដ្ឋប្បវេណី)។
- *តើត្រូវជូនដំណឹងដោយរបៀបណា?*
  - នៅក្នុងក្រមរដ្ឋប្បវេណី មិនបានកំណត់អំពីមធ្យោបាយនៃការជូនដំណឹងទេ
  - ធ្វើយ៉ាងណា "ការជូនដំណឹង" ត្រូវតែគ្មានការយឺតយ៉ាវ
  - តើត្រូវធ្វើជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់?

# ករណីយកិច្ចបន្តការគ្រប់គ្រង

- <u>ជាគោលការណ៍</u> អ្នកគ្រប់គ្រងដោយឈឺផ្ទាល ត្រូវបន្តការគ្រប់គ្រងរហូតដល់ពេលដែលសាមីខ្លួន សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់ របស់សាមីខ្លួននោះ អាចធ្វើការគ្រប់គ្រងបាន
- ការគ្រប់គ្រងត្រូវបានបញ្ចប់ដោយ៖
  - សាមីខ្លួន សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់សាមីខ្លួននោះ <u>***អាចធ្វើការគ្រប់គ្រង***</u> បាន។
  - ការបន្តការគ្រប់គ្រងនោះ ផ្ទុយនឹងឆន្ទៈរបស់សាមីខ្លួន
  - ការបន្តការគ្រប់គ្រងនោះ នឹងអាចធ្វើឱ្យខូចផលប្រយោជន៍សាមីខ្លួន

# ករណីយកិច្ចប្រគល់

- នៅពេលដែលការគ្រប់គ្រងត្រូវបានបញ្ចប់ អ្នកគ្រប់គ្រងមានករណីយកិច្ចត្រូវ ប្រគល់ទៅឱ្យសាមីខ្លួនវិញនូវ៖
  - ប្រាក់ និង វត្ថុផ្សេងទៀតដែលបានមកពីការគ្រប់គ្រង៖
  - ផល (ផលស៊ីវិល និង ផលធម្មជាតិ) ដែលអ្នកគ្រប់គ្រងបានទទួលតាមរយៈការគ្រប់គ្រង
  - សិទ្ធិដែលបានលទ្ធកម្មដើម្បីសាមីខ្លួន ក៏ត្រូវប្រគល់ទៅឱ្យសាមីខ្លួន

# ករណីយកិច្ចរាយការណ៍

- *តើអ្នកគ្រប់គ្រងដោយឈឺឆ្អាលត្រូវរាយការណ៍នៅពេលណា?*
  - ពេលបញ្ចប់ការគ្រប់គ្រងដោយឈឺឆ្អាល
  - សាមីខ្លួនបានទាមទារឱ្យរាយការណ៍
  - អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវរាយការណ៍ដោយគ្មានការយឺតយ៉ាវ
  - អ្នកគ្រប់គ្រង ត្រូវរាយការណ៍គ្រប់ពេលវេលា
- *តើអ្នកគ្រប់គ្រងដោយឈឺឆ្អាលត្រូវរាយការណ៍អំពីអ្វីខ្លះ?*
  - ស្ថានភាពនៃការគ្រប់គ្រងកិច្ចការ
  - ហេតុការណ៍នៃការគ្រប់គ្រង

# ករណីយកិច្ចរាយការណ៍ (ត)

- *តើការជូនដំណឹង និង ការរាយការណ៍ខុសគ្នាដូចម្ដេច?*

| ការជូនដំណឹង | ការរាយការណ៍ |
|---|---|
| អំឡុងពេលនៃការគ្រប់គ្រង | ការគ្រប់គ្រងត្រូវបានបញ្ចប់ |
| អវត្តមាននៃការទាមទាររបស់សាមីខ្លួន | លុះត្រាតែមានការទាមទារពីសាមីខ្លួន |
| ជូនដំណឹងអំពីការចាប់ផ្ដើម | រាយការណ៍អំពីស្ថានភាព និង ហេតុការណ៍ |

# ករណីយកិច្ចសងសំណងនៃការខូចខាត

ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺផ្កាល បានធ្វើការគ្រប់គ្រងដោយឈឺផ្កាល ដើម្បី បុគ្គលណាមួយ ហើយបានធ្វើឱ្យមានការខូចខាតដល់បុគ្គលនោះ ករណីនេះ អ្នកគ្រប់គ្រងដោយឈឺផ្កាល ត្រូវទទួលខុសត្រូវសងសំណងនៃការខូចខាត ដល់សាមីខ្លួន។

# ករណីយកិច្ចគ្រប់គ្រងដោយផ្អែកតាមឆន្ទៈរបស់សាមីខ្លួន ឬ តាមវិធីសមរម្យ

- <u>ករណីបានដឹង ឬ អាចដឹងអំពីឆន្ទៈ</u>៖ អ្នកគ្រប់គ្រង ត្រូវធ្វើការគ្រប់គ្រងដោយផ្អែកតាមឆន្ទៈរបស់សាមីខ្លួននោះ។
- <u>ករណីដែលមិនបានដឹង</u>៖ អ្នកគ្រប់គ្រង ត្រូវធ្វើការគ្រប់គ្រង ដោយព្យាយាមដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត តាមវិធីដែលសមរម្យជាគេ ដើម្បីប្រយោជន៍របស់សាមីខ្លួន ផ្អែកតាមលក្ខណៈនៃកិច្ចការ។

# សូមអរគុណ!

# សំណួរ-ចម្លើយ